**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

ទីស្តីការក្រសួងយុត្តិធម៌

លេខ ៥៨៨ ព្រទ-៩៨

# <u>សារាចរលេខ</u>

**<u>អ្នកទទួល:</u>** ប្រធានតុលាការ និងព្រះរាជអាជ្ញាខេត្ត-ក្រុងទូទាំងប្រទេស

**<u>ខ្លឹមសារ:</u>** យោងសារលេខ ១៩ ព្រទ.សទ-៩៨ ។

ខ្ញុំសូមបញ្ជាក់ថា ចំពោះបទល្មើសដែលកើតឡើងនៅក្នុងដែនដីសមត្ថកិច្ចរបស់អយ្យការ និងតុលាការព្រះរាជអាជ្ញាមិនត្រូវរង់ចាំនគរបាលរាយការណ៍ដូចពីមុនៗនោះទេ ដូចជានៅស្រុកមួយនៃខេត្តស្វាយរៀង អំពើប្លន់សម្លាប់មនុស្សបានកន្លងទៅមួយសប្តាហ៍ហើយ ហើយមានគេស្គាល់មុខជនល្មើស ប៉ុន្តែព្រះរាជអាជ្ញាមិនទាន់បានទទួលរបាយការណ៍ពីនគរបាលទេ ហើយមិនទាន់អាចចេញដីការកចាប់ខ្លួនបានឡើយ ។

ព្រះរាជអាជ្ញាត្រូវធ្វើទំនាក់ទំនងជាមួយស្នងការនគរបាលខេត្ត-ក្រុង ឱ្យមានការឯកភាពគ្នាថា កាលណាមានបទល្មើសអ្វីកើតឡើងនៅក្នុងខេត្ត ស្រុក ឃុំ ជាពិសេសបទល្មើសឧក្រិដ្ឋ នគរបាលត្រូវជូនដំណឹងមកព្រះរាជអាជ្ញាជាបន្ទាន់ទោះបីយប់ឬថ្ងៃ ដែលមានអ្នកយាមប្រចាំការគ្រប់ពេលវេលានៅតុលាការ ព្រះរាជអាជ្ញាត្រូវចុះទៅជាមួយនគរបាលផ្ទាល់ខ្លួនក្នុងករណីបទល្មើសឧក្រិដ្ឋ ដើម្បីស្វែងយល់ហើយបញ្ជាទីសអោយស្រាវជ្រាវ ហើយរាយការណ៍លំអិតទៅក្រសួងជាបន្ទាន់អំពីចំណាត់ការរបស់ខ្លួន ។

ព្រះរាជអាជ្ញា ឬចៅក្រមស៊ើបសួរត្រូវតាមដានឱ្យយ៉ាងស្អិតនូវលទ្ធផលនៃការស៊ើបអង្កេត ។ ព្រះរាជអាជ្ញាត្រូវបំពេញតួនាទីខ្លួនក្នុងស្មារតីទទួលខុសត្រូវខ្ពស់តាមមាត្រា ៥៦ នៃនីតិវិធីព្រហ្មទណ្ឌ ។ សូមលោកបញ្ជាក់មកក្រសួងឱ្យបានដឹងពីការលំបាកដែលជួបប្រទះ ដើម្បីអោយថ្នាក់លើមានវិធានការណ៍សមស្របជួយអន្តរាគមន៍ ។

ធ្វើនៅភ្នំពេញ ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ១៩៩៨

**រដ្ឋមន្ត្រី**

**ចែម ស្គួន**

<u>ចម្លងជូន</u>

-ទីស្តីការគណៈរដ្ឋមន្ត្រី

-ក្រសួងមហាផ្ទៃ

-អគ្គនាយកដ្ឋាននគរបាលជាតិ